គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia
និយ័តករបរធនបាលកិច្ច
Trust Regulator
លេខ ៤១ ចេញផ្សាយថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២
No.41 Released on April 12, 2022
អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# បរធនបាលដែលត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដើម្បីធ្វើប្រតិបត្តិការបរធនបាលកិច្ច

## A Licensed/Authorized Trustee to carry out Trust Operations




អនុលោមតាមប្រការ ១២ នៃប្រកាសស្តីពីវិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច បានបញ្ញត្តិថា“*គ្មានបុគ្គលណាមួយតាំងខ្លួន ឬធ្វើសកម្មភាពជាបរធនបាល ឬជាតំណាងបរធនបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លុះត្រាតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ពីអគ្គនាយកនៃ **ន.ប.ធ.***”។ ក្នុងន័យនេះផងដែរ បរធនបាលត្រូវបានឱ្យនិយមន័យ និងបែងចែកជា ២ ប្រភេទ។

- **និយមន័យ÷ បរធនបាល** សំដៅដល់ក្រុមហ៊ុនបរធនបាល ឬបរធនបាលជារូបវន្តបុគ្គល ដែលទទួលសិទ្ធិចាត់ចែង គ្រប់គ្រង និងថែរក្សាបរធនពីបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធន-បាលកិច្ច សម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។
- **ប្រភេទបរធនបាល÷**

**១. ក្រុមហ៊ុនបរធនបាល** សំដៅដល់បរធនបាលជានីតិបុគ្គល ដែលទទួលបានអាជ្ញាបណ្ណ និង/ ឬ ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន។

**២. បរធនបាលរូបវន្តបុគ្គល** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើជាបរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល ឬបរធនបាលរូបវន្តបុគ្គលឯករាជ្យ។ បរធនបាលរូបវន្តបុគ្គល ត្រូវបានចែកចេញជា ២ ប្រភេទគឺ÷

- **បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល** សំដៅដល់រូបវន្តបុគ្គល ដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើជាបរធនបាលរូបវន្តបុគ្គលក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាល។
- **បរធនបាលរូបវន្តបុគ្គលឯករាជ្យ** សំដៅដល់រូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន ហើយបរធនបាលរូបវន្តបុគ្គលឯករាជ្យនេះ មិនស្ថិតនៅក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ ឬការអនុញ្ញាតរបស់ក្រុមហ៊ុនបរធនបាលណាមួយឡើយ។

**បញ្ជាក់÷** បរធនបាលដែលត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត អាចធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយ ឬច្រើន ដូចខាងក្រោម÷

- ប្រតិបត្តិការបរធនបាលកិច្ចសាធារណៈ
- ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម
- ប្រតិបត្តិការបរធនបាលកិច្ចសង្គម
- ប្រតិបត្តិការបរធនបាលកិច្ចបុគ្គល និង
- ប្រតិបត្តិការបរធនបាលកិច្ចផ្សេងទៀតតាមការកំណត់របស់ **ន.ប.ធ.**។

អត្ថបទ៖ ស៊ិន សុមាល័យ | Article: SIN SOMALAY

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ៤១ ចេញផ្សាយថ្ងៃទី១២ ខែមេសា ឆ្នាំ២០២២
No.41 Released on April 12, 2022

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# បរធនបាលដែលត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ដើម្បីធ្វើប្រតិបត្តិការបរធនបាលកិច្ច

## A Licensed/Authorized Trustee to carry out Trust Operations




According to Article 12 of the Prakas on Rules for the Management, Organization and Functioning of Trust as set forth that any person shall not be considered as trustee or carry out any trust operation in the name of trustee or trustee's representative in the Kingdom of Cambodia, unless that person has been licensed/authorized by the Director General of Trust Regulator (**TR**). With this regard, trustee is clearly defined and divided into two categories.

- **Definition: Trustee** refers to a trust company or an individual trustee who has the rights to manage and safeguard keeping of trust funds from trust creator or contributor of trust fund for the benefits of beneficiary in accordance with trust deed/trust instrument or regulations in force.

- **Type of Trustee:**

**I. Trust Company** refers to a legal entity licensed/authorized by the Director General of the **TR** to carry out one or more trust operations.

**II. Individual Trustee:** refers to an individual person licensed by the **TR** to act as an Individual Trustee of Trust Company or Independent Individual Trustee. Individual Trustee is categorized into two types:

- **Individual Trustee of Trust Company:** refers to an individual person licensed by the **TR** in order to provide trust services and carry out the trust operation under a licensed trust company.

- **Independent Individual Trustee:** refers to an individual person licensed by of the **TR** in order to carry out one or more trust operations and this kind of trustee does not fall under the requirements of any licensed/authorized trust company.

**Notice:** A Licensed/Authorized Trustee shall conduct one or more Trust Operations as following:

- Public Trust Operation
- Financial Trust Operation
- Commercial Trust Operation
- Social Trust Operation
- Individual Trust Operation
- Other Trust Operation determined by the **TR**.

អត្ថបទ៖ ស៊ិន សុមាល័យ | Article: SIN SOMALAY

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.

ប្រកាសបដិសេធ៖ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.